# តង្វាយចំពោះអ្នកតាមេ-ស

ដូចបានដឹងស្រាប់ថា "អ្នកតាមេ-ស"[1] គឺជាអមនុស្សដែលអ្នកស្រុកជឿថាមាននាទីជាអ្នកតាធំប្រចាំស្រុក។[2] ជារៀងរាល់ឆ្នាំ គេតែងតែរៀបចំធ្វើបុណ្យឡើងអ្នកតាថ្វាយ ៣ យប់៣ថ្ងៃ នៅក្នុងរវាងចុងខ្នើតខែជេស្ឋ (ឆ្នាំនេះប្រារព្ធថ្ងៃ១៤-១៥កើត ដល់ថ្ងៃ ១ រោច ខែជេស្ឋ) ពោលគឺមុននឹងចូលដល់រដូវធ្វើស្រែ។ តាមព្រេងនិទាន គេតែងបូជាមនុស្សទុកជាតង្វាយសំខាន់ប្រចាំឆ្នាំដល់អ្នកតាមេ-ស ដើម្បីបួងសួងសូមឱ្យមនុស្ស និងសត្វក្នុងភូមិរស់នៅបានសុខសប្បាយ មានភ្លៀងធ្លាក់គ្រប់គ្រាន់។ ប៉ុន្តែតង្វាយនេះបានប្តូរផ្លាស់ជាបន្តបន្ទាប់ ហើយអ្នកស្រុកនិទានថាក្រោយមកទៀតគេតែងបូជាក្របី ឬជ្រូកជំនួសការបូជាមនុស្ស រហូតមកដល់សព្វថ្ងៃគេថ្វាយជ្រូកខ្វៃជាតង្វាយ។

ជាការពិត តាំងពីដើមរៀងមកទំនៀមបុណ្យឡើងអ្នកតាមេ-សតែងប្រារព្ធឡើងនៅជាប់ជើងភ្នំឈើកាច់ ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង ដែលនៅក្បែរនោះមានកូនភ្នំតូចមួយជាទីតម្កល់រូបសំណាកអ្នកតាមេ-ស (រូបលេខ១-២)។ មិនតែប៉ុណ្ណោះ គេតែងសម្គាល់ឃើញថាអ្នកមានសទ្ធាផ្តួចផ្តើមឧបត្ថម្ភគាំទ្រពិធីបុណ្យនេះ រាប់តាំងពីអ្នកស្រុកអ្នកភូមិ មន្ត្រីរាជការថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់ដឹកនាំជិតឆ្ងាយ និងសប្បុរសជនក្រៅប្រទេសផង។ ថ្ងៃទី១ គេហៅថាថ្ងៃក្រុងពាលី សូត្រមន្ត ឬជាទូទៅហៅសាមញ្ញថាថ្ងៃចូលរោង។ ក្នុងថ្ងៃនេះគេធ្វើកិច្ចក្រុងពាលីនៅវេលារសៀល បន្ទាប់មកគឺការចុះសំណេះសំណាលសួរសុខទុក្ខរវាងថ្នាក់ដឹកនាំ ជាមួយប្រជាពលរដ្ឋនៅតាមរោងមណ្ឌល និងរោងបុណ្យប្រចាំឃុំនីមួយៗ។ ថ្ងៃទី២ គេហៅថា "ថ្ងៃហែ" ជាថ្ងៃប្រាព្ធកិច្ចដង្ហែគ្រឿងសក្ការៈ និងតង្វាយចេញពីរោងបុណ្យឆ្ពោះទៅកាន់ខ្ទមអ្នកតាមេ-ស។ ចំណែកឯថ្ងៃទី៣ គឺជា "ថ្ងៃធ្វង" មានកិច្ចរាប់បាត្រព្រះសង្ឃច្រើនរយអង្គធ្វើបុណ្យនៅវេលាព្រឹក ក្រោមវត្តមានអ្នកមុខអ្នកការតូចធំផង។

---

[1] សូមអានបន្ថែម៖ "អ្នកតាមេ-ស" ភាគ១-២ ដោយ ហៀន សុវណ្ណមរកត ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/22674 (ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២) និង https://ams.com.kh/khmercivilization/detail/22796 (ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២)។

[2] តាមប្រជុំរឿងព្រេងខ្មែរភាគ៨ នៅជុំវិញអ្នកតាមេ-ស មានអ្នកតាទ្វារ អ្នកតាទូងស្គរ អ្នកតានាងត្រដាច អ្នកតាសម្តេងកែវ អ្នកតាព្រះស្រែ អ្នកតាព្រះស្រុក អ្នកតាបុះលៀន អ្នកតាច្រកចំបក់ និងអ្នកតាសូន្យយក្ស។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត





រូបលេខ២១ កូនភ្នំអាស្រមអ្នកតាមេ-ស

រូបលេខ២២ រូបសំណាកអ្នកតាមេ-ស

ចំពោះទំនៀមឡើងអ្នកតាខាងលើនេះ គេក៏ពុំដឹងថាចាប់ប្រារព្ធពីត្រឹមសម័យណាឡើយ។ ប៉ុន្តែចូលមកដល់សម័យសង្គ្រាម ទំនៀមនេះបានផ្អាក ហើយរហូតដល់រវាងឆ្នាំ១៩៩៥ ទើបអ្នកស្រុកជិតឆ្ងាយបានមូលមាត់គ្នាសង់ខ្ទមថ្មីជំនួសខ្ទមចាស់ (រូបលេខ២៣) ព្រមទាំងចាប់ផ្ដើមរៀបចំធ្វើបុណ្យឡើងអ្នកតាមេ-សតាមទំនៀមឡើងវិញ ហើយសព្វថ្ងៃនៅក្នុងខ្ទមអ្នកតាមេ-ស គេឃើញមានបដិមាធំបីតម្កល់ជាជួរទន្ទឹមគ្នាលើបល្ល័ង្កកម្ពស់ត្រឹមចង្កេះ។ លើសពីនេះ ក្នុងឆ្នាំ២០១១ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានកំណត់កូនភ្នំនោះជាស្ថានីយបុរាណក្នុងន័យថែរក្សា និងអភិរក្ស។ មិនតែប៉ុណ្ណោះ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈថែមទាំងបានរៀបចំដំឡើង"របាំឡើងអ្នកតាមេ-ស" ជាទម្រង់សិល្បៈទស្សនីយភាពសម្រាប់សម្ដែងបង្ហាញសាធារណជនទស្សនាកម្សាន្ត និងស្វែងយល់ពីទំនៀមបុណ្យនេះផងដែរ (រូបលេខ២៤-៥)។





រូបលេខ២៣ ខ្ទមចាស់តម្កល់រូបសំណាក អ្នកតាមេ-ស (ប្រភព៖ ?)

រូបលេខ២៤-៥ របាំឡើងអ្នកតាមេ-ស (ប្រភព៖ ភ្នំពេញប៉ុស្តិ៍)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*បើតាមការនិទានក្នុងប្រជុំរឿងព្រេងរំឭកទៅរវាងចុងសតវត្សទី១៩ថា កាលពីដើម គេធ្វើពេធិ៍បុណ្យនៅទីវត្តវិហារធំ ព្រមទាំងនិមន្តព្រះសង្ឃដារនៅទីអ្នកតាផ្សេងៗដូចជា អ្នកតាមេ-ស អ្នកតាក្រហមក (ខាងជើងភ្នំ) អ្នកតាសព្វឋាន (ត្រង់ចង្កេះភ្នំខាងលិច) និង អ្នកតាទួលឈ្នាង (លើភ្នំទួលឈ្នាង)ៗ[3] ដោយឡែក ចំពោះតង្វាយអ្នកតាមេ-សពីបុរាណ កាលដែលអ្នកស្រុកចងចាំគឺការសម្លាប់មនុស្សបូជា (រូបលេខ៦)។ និទាននោះនិយាយថា មនុស្សដែលត្រូវសម្លាប់ គឺយកមនុស្សណាមានទោសធ្ងន់។ មុននឹងសម្លាប់ គេបានប្រាប់ សាមីខ្លួនឱ្យដឹងជាមុន ឱ្យស៊ីផឹកឆ្ងាញ់តាមចំណង់ នាំមើលល្បែង មើលបុណ្យធម្មតាដូច មនុស្សគ្មានទោស។ លុះដល់ថ្ងៃសម្លាប់ គេរៀបចំដាក់ឃ្នាង ដង្ហែចេញពីទីប្រជុំបុណ្យ យ៉ាងអធឹកអធម មានទាហានកាន់សាស្ត្រាវុធ ឬកាំភ្លើងមុខក្រោយ ព្រមដោយអ្នកស្រុក រាប់ពាន់នាក់ហែទៅកាន់ទីអ្នកតាមេ-ស។ ដល់ហើយ គេរៀបចំបួងសួងបន់ស្រន់សូមឱ្យ អ្នកតាមេ-សជួយឱ្យស្រុកបានសុខសប្បាយ ជួយរក្សាអភិបាលស្រុក នាម៉ឺនសព្វមុខមន្ត្រី និងបណ្ដារាស្ត្រ ព្រមទាំងឱ្យទឹកភ្លៀងធ្លាក់ចុះមកតាមរដូវកាល ។ល។ រួចហើយ គេស្រែក ភូមា (យក្សអើ!) ៣ដង ទើបអ្នកសម្លាប់ កាន់ដាវរាំរែកក្រឡឹងជុំវិញអ្នកទោសនោះ ងារដាវ កាប់តែ១ ខ្ទាប់ដាច់កតែម្ដង។*

*ការសម្លាប់មនុស្សបូជាអ្នកតាមេ-សនេះ គេសម្គាល់មើលថា បើឈាមបាញ់ទៅលើ ទៅខាងស្មើគ្នា ថាទឹកភ្លៀងនឹងធ្លាក់ស្មើគ្រប់ស្រុក។ ប៉ុន្តែបើឈាមបាញ់ទៅតែខាងណា ច្រើនជាង គេជឿថាភ្លៀងនឹងធ្លាក់តែនៅស្រុកនោះចំទិសនោះច្រើនដែរ។ ទន្ទឹមនឹងនេះ ក្នុងពេលដំណាលគ្នានោះ មានបាញ់កាំភ្លើង អុជផាវ យ៉ាងគគ្រឹកគគ្រេងផង។ ចំណែក ក្រុមដែលនៅទីអ្នកតាក្រហមក អ្នកតាសព្វឋាន និងអ្នកតាទួលឈ្នាង ត្រូវបាញ់កាំភ្លើង និងអុជផាវគំនាប់តាមក្រោយ បន្ទាប់ពីឮស្នូរកាំភ្លើងនៅទីអ្នកតាមេ-ស។ ចំពោះមនុស្ស ដែលគេសម្លាប់ហើយ គេយកក្បាល និងអារសាច់១០០ច្រនួចដោតថ្វាយអ្នកតាមេ-ស និងអ្នកតាទាំងបីផ្សេងទៀត៥០ ច្រនួចស្មើៗគ្នា។[4]*

---

[3] *ឯកសារនេះសរសេរក្នុងឆ្នាំ១៩៤៤ តាមការរំឭករឿង៦០ឆ្នាំមុន របស់លោកតាអតីតអភិបាលស្រុក កំពង់ត្របែក (ប្រជុំរឿងព្រេងខ្មែរ ភាគ៨ បោះពុម្ពផ្សាយឆ្នាំ១៩៨០ ទំ.៨៣)*

[4] *ប្រជុំរឿងព្រេងខ្មែរ ភាគ៨, ១៩៨០: ៨៣-៨៧*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*



រូបលេខ២៦ គំនូរបង្ហាញទិដ្ឋភាពសម្លាប់មនុស្សថ្វាយអ្នកតាមេ-សផ្អែកតាមសៀវភៅប្រជុំរឿងព្រេងខ្មែរ (គំនូរ៖ កញ្ញា ចាន់ រស្មី)

ទោះយ៉ាងណាក្ដី មកដល់បច្ចុប្បន្នពុំមាននរណាម្នាក់អះអាងថាធ្លាប់បានឃើញទិដ្ឋភាពបូជាមនុស្សដូចក្នុងនិទានខាងលើដោយផ្ទាល់ភ្នែកឡើយ។ ប៉ុន្ដែក្នុងនិទានខាងលើបន្ដថាការបូជាថ្វាយអ្នកតានេះ ក្រោយមកគេជ្រើសយកក្របីឡើងកជំនួសវិញ។ ការសម្លាប់ក្របីនោះសោត គេក៏សម្គាល់ប្រផ្នូលឈាមដូចសម្លាប់មនុស្សដែរ។ បន្ទាប់មកសាច់ក្របីនោះគេចែក១០០ប្រនួចថ្វាយអ្នកតាមេ-ស ភ្លៅ១ថ្វាយអ្នកតាក្រហមក និងភ្លៅ១ទៀតថ្វាយអ្នកតាសព្វឋាន។ លុះប្រហែលត្រឹមឆ្នាំ១៩២០ គេឈប់សម្លាប់ក្របី ដោយសម្លាប់ជ្រូកជំនួសវិញ ហើយប្រហែលក្នុងរវាងដើមទសវត្សរ៍ទី៤០ គេយកសាច់ជ្រូក១០០ប្រនួចទៅថ្វាយតែម្ដង។

ដោយឡែក គេពុំចាំឡើយថាទំនៀមថ្វាយតង្វាយដូចរៀបរាប់ខាងលើបានបន្តមកដល់ត្រឹមឆ្នាំណាឡើយ។ ប៉ុន្ដែចាប់ពីរវាងដើមឆ្នាំ២០០០ គេសង្កេតឃើញអ្នកស្រុករៀបចំថ្វាយជ្រូកមួយទាំងមូល។ ជ្រូកនោះគេសម្លាប់ពីនាយមក ដោយគ្រាន់តែកោសសម្អាតហើយធ្វើវាមិនឱ្យឆ្អិនឡើយ ពោលគឺនៅឃើញរូបរាងជាជ្រូកមួយតែម្ដង (រូបលេខ២៧)។ ផុតពីការថ្វាយជ្រូកឆៅ គេបានរៀបចំថ្វាយជ្រូកខ្វៃវិញ (រូបលេខ២៨)។ ចំពោះតង្វាយជ្រូក

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ខ្វៃនេះ គេសម្គាល់ឃើញថាក្នុងឆ្នាំខ្លះមានជ្រូកខ្វៃរហូតដល់៥ ទៅ៦ ក្បាល គឺអាស្រ័យតាមសទ្ធា ឬអ្នកមានជំនឿរៀបចំយកមកចូលរួម។ ប៉ុន្តែក្នុងឆ្នាំខ្លះ មានត្រឹមតែជ្រូកខ្វៃមួយប៉ុណ្ណោះ ពោលគឺរៀបចំមិនឱ្យសោះខានឡើយ។ តង្វាយជ្រូកខ្វៃនេះ គេឃើញមានជាហូរហែរហូតមកដល់សព្វថ្ងៃ។ ប្រភេទតង្វាយចុងក្រោយនេះ បន្ទាប់ពីធ្វើកិច្ចបួងសួងថ្វាយរួចរាល់ហើយ គេត្រូវបែងចែកទៅតាមរោងមណ្ឌល និងរោងប្រចាំឃុំនីមួយៗផងដែរ។ រីឯតង្វាយដទៃទៀតក្រៅពីនេះ គេឃើញថាពុំសូវមានអ្វីធំដុំឡើយ មានបាយសីច្រើនថ្នាក់ស្អេកស្កះទេ ពោលគឺមានតែផ្កាឈូក ផ្លែឈើ និងការរៀបចំថ្វាយភ្លេងក្នុងកិច្ចបួងសួងសុំសេចក្ដីសុខតែប៉ុណ្ណោះ។


រូបលេខ២៧ ជ្រូកដែលគេសម្លាប់ថ្វាយអ្នកតាមេ-ស ក្នុងពិធីបុណ្យកាលដើមឆ្នាំ២០០០ (រូប៖ MCFA)


រូបលេខ២៨ ជ្រូកខ្វៃជាដង្វាយរៀបចំជាដង្វាយសម្រាប់អ្នកតាមេ-ស ក្នុងពិធីបុណ្យសព្វថ្ងៃ

សូមបញ្ជាក់ថាក្នុងពិធីឡើងអ្នកតាមេ-ស ពុំមានកិច្ចបញ្ចូលបញ្ជាន់រូបទេ ម៉្យោះហើយពុំឃើញមានរូបសំណឹងឡើយ ពោលគឺមានតែកិច្ចសែនព្រេនបួងសួងថ្វាយតង្វាយប្រចាំឆ្នាំ គ្រឿងសក្ការបូជាផ្សេងៗ និងថ្វាយភ្លេងតាមទំនៀមតែប៉ុណ្ណោះ។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់ គឺចុងឃ្លានៃសេចក្ដីបួងសួងនីមួយៗ គេតែងឮពាក្យ "សុំឱ្យសុខសប្បាយ សូមឱ្យមន្ត្រីរាជការ និងថ្នាក់ដឹកនាំឱ្យឡើងបុណ្យ ឡើងស័ក្តិ ឡើងយស..."។ ឃ្លានេះអ្នកស្រុកពន្យល់ថាបើថ្នាក់ដឹកនាំណាម្នាក់ពុំអើពើ ពុំចូលរួមរៀបចំពិធីឡើងអ្នកតាមេ-សច្រើនតែជួបគ្រោះ មានធ្លាក់បុណ្យ ធ្លាក់តំណែងជាដើម។

សរុបមក តង្វាយសំខាន់ចំពោះអ្នកតាមេ-សពីដើមមក គឺជានិទានមួយរបស់អ្នកស្រុក។ ប៉ុន្តែប្រសិនបើគេល្បងពិចារណាខ្លះ ហាក់ដូចជាតង្វាយទាំងអស់នោះបង្ហាញឱ្យ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ឃើញពីទំនាក់ទំនងឈាម ឬសាច់ស្រស់ចំពោះអមនុស្ស ទោះបីជាតង្វាយនោះប្តូរពីការសម្លាប់មនុស្សមកសម្លាប់ក្របី ឬជ្រូកក្តី។ មិនតែប៉ុណ្ណោះ បើគេពិនិត្យរូបបដិមាសំខាន់តម្កល់ក្នុងខ្ទមអ្នកតាមេ-ស ធៀបនឹងការបូជាមនុស្ស ឬក្របី គេអាចស្រមៃឃើញដល់ទេពកថានៃនាងទុគ៌ា ជាមហេសីព្រះឥសូរ ជាទេពធ្មើមខាងច្បាំងប្រយុទ្ធ ជាពិសេសនៅក្នុងសិល្បៈខ្មែរ គេតែងឆ្លាក់រំលេចត្រង់ពេលនាងសម្លាប់បិសាចកាឡាខ្លួនជាក្របី (*Durgā Mahiṣāsuramardinī*)។[5] រីឯការរៀបចំតង្វាយជ្រូកខ្វៃសព្វថ្ងៃនេះ ហាក់ដូចជាខិតជិតទៅរកការនិយមតាមបែបទំនើបដែលមានស្រាប់ ឬជាតង្វាយដែលឆ្លងពីអារ្យធម៌ចិនមកខ្មែរ។

## ឯកសារយោង


ក្រុមជំនុំជំនៀមទម្លាប់ខ្មែរ

១៩៨០, *ប្រជុំរឿងព្រេងខ្មែរ*, ភាគ៨, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ហៀន សុវណ្ណមរកត

២០២២, "អ្នកតាមេ-ស" ភាគ១-២, ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/22674 (ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២) និង https://ams.com.kh/khmercivilization/detail/22796 (ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២)។

Cornelia Dimmitt & J. A. B. van Buitenen

1978, *Classical Hindu Mythology; A Reader in the Sanskrit Purāṇas,* Temple University Press, Philadelphia

Thierry Zéphir

1997, "Introduction to Khmer Sculpture: General Remarks", *Sculpture of Angkor and Ancient Cambodia,* pp. 130-345, National Library of Art, Washington


[5] Cornelia Dimmitt & J. A. B. van Buitenen 1978: 237 & Thierry Zéphir 1997: 168

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត